**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ
នីហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ
(កាំកុងត្រូល)

## ការឆ្លើយតបចំពោះការលើកឡើងអំពីបញ្ហាសុវត្ថិភាពម្ហូបអាហារដោយទណ្ឌិត សម រង្ស៊ី

អ្វីដែលទណ្ឌិតសម រង្ស៊ី លើកឡើងគ្រាន់តែជាការកេងចំណេញផ្នែកនយោបាយ បំពានការពិតទាំងងងឹតងងុល គ្មានដឹងពីស្ថានភាពពិត និងអ្វីដែលរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា បាន និងកំពុងធ្វើ និងទទួលផលពីការខិតខំចូលរួមគ្រប់ភាគីពាក់ព័ន្ធ ពិសេសលើបញ្ហាសុវត្ថិភាពម្ហូបអាហារ។

ចំពោះបញ្ហាពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ រាជរដ្ឋាភិបាល បានរៀបចំគ្រប់គ្រាន់ និងច្បាស់លាស់ប្រកបដោយលក្ខណៈបច្ចេកទេស និងវិទ្យាសាស្ត្រ ដើម្បីធានាសុវត្ថិភាព សុខភាព ព្រមទាំងការផ្តល់ឲ្យបានពេញលេញនូវអាហារមានគុណភាពជូនប្រជាពលរដ្ឋ ក្នុងនោះរាជរដ្ឋាភិបាល បានរៀបចំ៖

១. ច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធ ស្តង់ដារទំនិញ យន្តការសម្រាប់ការអនុវត្តនានា ដោយរាប់ទាំងការគ្រប់គ្រង ត្រួតពិនិត្យផលិតផលទំនិញម្ហូបអាហារ បន្លែ ត្រីសាច់ នាំចូល ទំនិញចរាចរចែកចាយលក់ដូរនៅលើទីផ្សារ ។ល។
២. ស្ថាប័ន ក្រសួង អង្គភាព ទទួលខុសត្រូវច្បាស់លាស់ និងមានវិជ្ជាជីវៈលើបញ្ហាសុវត្ថិភាពម្ហូបអាហារ
៣. មន្ទីរពិសោធន៍ (មានទាំងមន្ទីរពិសោធន៍ខ្នាតធំ មន្ទីរពិសោធន៍ខ្នាតតូចដាក់នៅតាមមាត់ច្រកព្រំដែន មន្ទីរពិសោធន៍ចល័ត ឧបករណ៍វិភាគបឋម"Test Kit"សម្រាប់សមត្ថកិច្ចកាំកុងត្រូលប្រើប្រាស់វិភាគនៅនឹងកន្លែងភ្លាមៗ ទាំងនៅមាត់ច្រកនាំចូល និងលើទីផ្សារ)
៤. កម្មវិធីអប់រំផ្សព្វផ្សាយ លើកកំពស់ការយល់ដឹងជូនបងប្អូនប្រជាពលរដ្ឋ សិស្សានុសិស្ស អាជីវករ ពាណិជ្ជករ អ្នកលក់ដូរ តាមគ្រប់រូបភាព គ្រប់ទម្រង់ មានទាំងផ្ទាំងឃោសនា ខិតប័ណ្ណ ចម្រៀងអប់រំ ស្ពត់អប់រំ ឈុតឆាកកំប្លែង ជាដើម។ ជាងនេះទៅទៀត មន្ត្រីជំនាញរបស់កាំកុងត្រូលមានវត្តមានប្រចាំការនៅតាមបណ្តាទីផ្សារ ដើម្បីបង្ករលក្ខណៈងាយស្រួលក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារជូនប្រជាពលរដ្ឋ អាជីវករ អ្នកលក់ដូរ ទទួលបានទំនុកចិត្ត និងភាពកក់ក្តៅក្នុងការលក់-ទិញទំនិញម្ហូបអាហារ ទៀតផង។
៥. កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរសុវត្ថិភាពម្ហូបអាហារនៃបណ្តាប្រទេសនានាលើពិភពលោក ដើម្បីទទួលបានព័ត៌មាន និងវិធានការណ៍ទាក់ទិននឹងការហៅត្រឡប់ពីផ្សារនូវទំនិញម្ហូបអាហារមិនមានសុវត្ថិភាព ដែលក្នុងនោះសហរដ្ឋអាមេរិក ធ្លាប់មានបាតុភាពនេះដែរ ហើយបើតាមតួលេខពីអង្គការសុខភាពពិភពលោក (WHO) បង្ហាញថាមានករណីពុលចំណីអាហារ បណ្តាលឲ្យមានជនរងគ្រោះឈឺ និងបាត់បង់អាយុជីវិត កើតមានជាច្រើនករណីក្នុងមួយឆ្នាំៗនៅសហរដ្ឋអាមេរិក។

ចំពោះមតិលើកឡើងរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ឲ្យបងប្អូនប្រជាពលរដ្ឋធ្វើពហិការចំពោះម្ហូបអាហារដែលមានលួចលាយសារធាតុគីមីហាមឃាត់នោះគឺ **សម្តេចតេជោ** មានបំណងឲ្យបងប្អូនប្រជាពលរដ្ឋទាំងអស់មានការប្រុងប្រយ័ត្ន ចេះមើល ចេះជ្រើសរើស ផលិតផលទំនិញម្ហូបអាហារឲ្យបានសមស្របប៉ុណ្ណោះ ពីព្រោះបញ្ហាសុវត្ថិភាពម្ហូបអាហារ គឺជាបញ្ហារបស់យើងទាំងអស់គ្នា ដែលនោះ គឺជាអ្វីដែលប្រទេសជឿនលឿនគេក៏ធ្វើដូចគ្នានឹងកម្ពុជាអញ្ចឹងដែរ។

ចំពោះការលើកបង្ហាញពីការធ្វើការរបស់មន្ត្រីមន្ទីរពិសោធន៍នៅស្រុកគេ ក៏គ្រាន់តែចង់សម្ញែង អួតអាង បំភ្លៃការពិតថា មានតែស្រុកអាមេរិក ឬប្រទេសនេះ ប្រទេសនោះ ហើយមកបង្អាប់បង្អោនជាតិសាសន៍កម្ពុជាយើងប៉ុណ្ណោះ ហើយដែលជាក់ស្តែង កម្ពុជាមានមន្ទីរពិសោធន៍ម្ហូបអាហារដែលមានសមត្ថភាពវិភាគឃើញសារជាតុគីមី មេរោគចម្លង កត្តាគ្រោះថ្នាក់ជារូបវន្តផ្សេងៗ មិនចាញ់ប្រទេសជឿនលឿន ទាំងលើឧបករណ៍សម្ភារៈយកមកបំពាក់ប្រើប្រាស់នៅមន្ទីរពិសោធន៍ និងមន្ត្រីជំនាញ សុទ្ធតែបាន ឆ្លងកាត់ការរៀនសូត្រ មានបទពិសោធន៍ពីក្នុង និងក្រៅប្រទេស។

កន្លងទៅ ជនអមិត្ត ដែលមាននិន្នាការប្រឆាំងរាជរដ្ឋាភិបាលកម្ពុជា បានបង្កើតនូវព័ត៌មាន រូបភាព ឬការអធិប្បាយអគតិ តាមបណ្តាញព័ត៌មាន ពិសេសបណ្តាញសង្គមហ្វេសប៊ុក មកបំពុលសង្គម ធ្វើឲ្យស្ថានភាពច្របូកច្របល់ តាមរយៈការលើកយក បញ្ហាសុវត្ថិភាពម្ហូបអាហារមកបង្កើតជាបញ្ហា ក្នុងនោះគេបានប្រឌិតឡើងបញ្ហាអង្ករផ្លាស្ទិក បញ្ហាយាហ៊ីកៅស៊ូ ទឹកស៊ុបគីមី ប្រេង ឆាគីមី ជាដើម ហើយដែលសមត្ថកិច្ចកាំកុងត្រូល ដាក់វិធានការណ៍ស្រាវជ្រាវ បង្ក្រាប និងវែកមុខបានជនខិលខូចមកទទួលខុស ត្រូវចំពោះមុខច្បាប់ និងមិនមានការរកឃើញ ឬទទួលបានទំនិញមិនប្រក្រតីទាំងនោះពីភាគីណាមួយឡើយ។